**ឯកសារស្រាវជ្រាវសង្ខេប**

ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១

# ការកសាង និងអនុវត្តផែនការអភិវឌ្ឍ ៥ឆ្នាំ និងកម្មវិធីវិនិយោគ ៣ ឆ្នាំរំកិលនៅសង្កាត់នៅភ្នំពេញ


ស្រាវជ្រាវដោយ៖ កញ្ញា តាន់ សុគន្ធកល្យាណ

ដោយមានការចូលរួមពី៖ លោក ឆន ប៉ូល

លោក ថេង ណាន

កញ្ញា ហាស់ យុននារី



ខែវិច្ឆិកា ឆ្នាំ២០១៦

**វិទ្យាស្ថានសភាកម្ពុជា**

# កំណត់សម្គាល់

វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក) គឺជាស្ថាប័នឯករាជ្យមួយដែលផ្តល់ការគាំទ្រដល់សភាកម្ពុជា តាមរយៈការផ្តល់នូវឯកសារស្រាវជ្រាវទៅតាមសំណើរបសសមាជិក-សមាជិកា និងគណៈកម្មការជំនាញរបស់រដ្ឋសភា-ព្រឹទ្ធសភា ដែលមានការវិភាគទៅលើបញ្ហាដែលកំពុងតែកើតមាននៅពេលបច្ចុប្បន្ន និងដែលអាចនឹងកើតឡើងនាពេលអនាគត លើប្រធានបទការរៀបចំច្បាប់និងគោលនយោបាយសាធារណៈ។ ឯកសារទាំងនេះផ្តល់នូវព័ត៌មានផ្សេងៗដែលពាក់ព័ន្ធនឹងការងារសភា និងការងារមណ្ឌល ឬភូមិភាគរបស់សមាជិក-សមាជិកាសភា ក៏ប៉ុន្តែ រាល់អត្ថន័យដែលមាននៅក្នុងឯកសារទាំងនេះមិនមែនតំណាងឬឆ្លុះបញ្ចាំងអំពីទស្សនៈផ្ទាល់របស់វិទ្យាស្ថានសភាកម្ពុជា សភា ឬសមាជិក-សមាជិកាណាម្នាក់នោះឡើយ។

ខ្លឹមសារនៃឯកសារទាំងនេះមានកំណត់នូវកាលបរិច្ឆេទរៀបចំច្បាស់លាស់ និងអាចប្រើប្រាស់សម្រាប់តែជាឯកសារយោងប៉ុណ្ណោះ។ ឯកសារទាំងនេះមិនមានគោលបំណងផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬទៅលើគោលនយោបាយណាមួយឡើយ ហើយក៏មិនបានធ្វើការសិក្សាអោយបានគ្រប់ប្រធានបទ ឬរាល់ខ្លឹមសារលម្អិតដែលពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងនោះដែរ។

ខ្លឹមសារនៃគេហទំព័រនេះស្ថិតក្រោមច្បាប់ជាធរមានរបស់កម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ។ រាល់ការរៀបចំឡើងវិញដោយដកស្រង់នូវផ្នែកណាមួយ ឬខ្លឹមសារទាំងស្រុងនៃឯកសារនៅក្នុងគេហទំព័រនេះ ត្រូវមានការអនុញ្ញាតពីវិទ្យាស្ថាន។

រក្សាសិទ្ធិ ឆ្នាំ២០១៦ វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក)

# មាតិកា


១. សេចក្តីផ្តើម ........ 1

២. ផែនការអភិវឌ្ឍន៍ ៥ឆ្នាំ និងកម្មវិធីវិនិយោគ ៣ ឆ្នាំរំកិល ........ 1

៣. គោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ........ 2

៤. ការចូលរួមរបស់សង្កាត់ក្នុងការងារចុះឈ្មោះបោះឆ្នោត ........ 5

៥. សេចក្តីសន្និដ្ឋាន ........ 6

ឯកសារយោង ........ 7

## ១. សេចក្តីផ្តើម

ឯកសារស្រាវជ្រាវសង្ខេបនេះ ត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងសំណើររបស់ ភូមិភាគ ទី១ ប្រចាំព្រឹទ្ធសភា ដែលនឹងរៀបចំវេទិកាស្តីពី "បូកសរុបលទ្ធផលការអនុវត្តផែនការអភិវឌ្ឍន៍មូលដ្ឋាន សង្កាត់ និងថ្នាក់ក្រោមជាតិធានានូវសុវត្ថិភាពមូលដ្ឋាន" នៅខែធ្នូ ឆ្នាំ២០១៦។ សម្រាប់ជំនួយស្មារតី ក្នុងការរៀបចំវេទិកា ឯកសារស្រាវជ្រាវសង្ខេបនេះ ផ្តល់នូវព័ត៌មានដូចខាងក្រោម៖ (១) ភាពជោគជ័យ និងបញ្ហាប្រឈមពាក់ព័ន្ធទៅនឹង ផែនការអភិវឌ្ឍន៍ ៥ឆ្នាំ និងកម្មវិធីវិនិយោគ ៣ឆ្នាំរំកិល នៃសង្កាត់នៅ ក្នុងរាជធានីភ្នំពេញ (២) សមិទ្ធផល និងបញ្ហាប្រឈមនៅក្នុងការធ្វើអត្តសញ្ញាណប័ណ្ណ និងការចុះ ឈ្មោះបោះឆ្នោតនៅថ្នាក់សង្កាត់ (៣) បច្ចុប្បន្នភាពស្តីពីការអនុវត្តគោលនយោបាយភូមិ ឃុំ មាន សុវត្ថិភាពដែលផ្តោតទៅលើយុទ្ធសាស្ត្រអប់រំ យុទ្ធសាស្ត្របង្ក្រាប និងយុទ្ធសាស្ត្រទប់ស្កាត់ការប្រើ ប្រាស់ថ្នាំញៀនខុសច្បាប់។

សូមកត់សំគាល់ថា ការរៀបចំឯកសារស្រាវជ្រាវសង្ខេបនេះត្រូវបានធ្វើឡើងតាមរយៈប្រព័ន្ធអ៊ីនធឺណែត ឬឯកសារដែលមានស្រាប់តែប៉ុណ្ណោះ។ ខណៈពេលដែលក្រុមការងារ ព្យាយាមស្រាវជ្រាវរកឯកសារ ដែលពាក់ព័ន្ធ ប៉ុន្តែពុំអាចរកបានឯកសារដែលបោះពុម្ពផ្សាយឆ្នាំ២០១៥ ឬ ២០១៦។ ហេតុដូចច្នេះ ហើយ ឯកសារស្រាវជ្រាវសង្ខេបនេះនឹងផ្តល់ជូននូវព័ត៌មាន ឬទិន្នន័យដែលអាចរកបាន និងដែល បោះពុម្ពផ្សាយឆ្នាំមុននេះបន្តិច ដែលអាចចាត់ទុកជាឯកសារជំនួយស្មារតីសម្រាប់វេទិកា។

## ២. ផែនការអភិវឌ្ឍន៍ ៥ឆ្នាំ និងកម្មវិធីវិនិយោគ ៣ ឆ្នាំរំកិល

ផ្នែកនេះ ពិនិត្យមើលដោយសង្ខេប លើលទ្ធផល និងការប្រឈមនៃការអនុវត្តផែនការអភិវឌ្ឍន៍ ៥ ឆ្នាំ និងកម្មវិធីវិនិយោគ ៣ឆ្នាំរំកិល របស់សង្កាត់នៅភ្នំពេញ។

បើយោងតាមរបាយការណ៍ត្រីមាសឆ្នាំ ២០១២ ស្តីពីការអនុវត្តកម្មវិធីវិនិយោគ បីឆ្នាំរំកិលរបស់ ការិយាល័យផែនការ និងវិនិយោគនៃសាលារាជធានីភ្នំពេញ[1] (ដែលបោះពុម្ពផ្សាយដោយ NCDD) ក្រុមប្រឹក្សាសង្កាត់មានចំណេះដឹង និងអាចកសាង និងអនុវត្តដោយត្រឹមត្រូវនូវផែនការអភិវឌ្ឍន៍ ៥ឆ្នាំ និងកម្មវិធីវិនិយោគ ៣ឆ្នាំរំកិល។

ទាក់ទងទៅនឹងការអនុវត្តគម្រោងដែលប្រើប្រាស់ថវិកាសង្កាត់នៅឆ្នាំ ២០១៥ កិច្ចសន្យាចំនួន ១០១ នៃគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធត្រូវបានចុះហត្ថលេខា ប៉ុន្តែរហូតមកដល់ពេលនេះ (ខែវិច្ឆកា ឆ្នាំ ២០១៦) គ្មានកិច្ចសន្យាណាត្រូវបានអនុវត្តទេ។[2] នៅឆ្នាំ ២០១៤ កិច្ចសន្យាចំនួន ៩៧ ត្រូវបានចុះ ហត្ថលេខា ប៉ុន្តែគម្រោងចំនួន ៦៦ ត្រូវបានអនុវត្ត 100% គម្រោងចំនួន ៣ ត្រូវបានអនុវត្តបាន

៥០%  និងគម្រោងចំនួន ២៨ មិនត្រូវបានអនុវត្ត។ មិនមានមូលហេតុជាក់លាក់ណាមួយត្រូវបានលើកឡើងទេ[3] អាស្រ័យហេតុនេះ ទាមទារការស្រាវជ្រាវបន្ថែមទៀតដើម្បីរកអោយឃើញពីមូលហេតុ។

បើយោងតាមរបាយការណ៍របស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទីមួយ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ ២០១៦ ការប្រឈមរួមមានដូចខាងក្រោមះ

- បញ្ហាការដកថវិកាដោយសារសង្កាត់មិនទាន់យល់ច្បាស់ពីនីតិវិធីនៃការដកប្រាក់ជាមុនច្បាស់ ដោយសារតែការធ្វើកំណែទម្រង់នាពេលថ្មីៗនេះ។
- សមត្ថភាពនៅមានកម្រិត ហើយទំហំការងាររបស់ស្មៀនសង្កាត់កាន់តែមានទំហំធំឡើងៗ ដែលនាំអោយមានការយឺតយ៉ាវក្នុងការដកប្រាក់។[4]
- មិនមានចំនួនក្រុមហ៊ុនគ្រប់គ្រាន់ចូលរួមក្នុងការដេញថ្លៃគម្រោង។
- ថវិកាសង្កាត់មិនគ្រប់គ្រាន់ដែលជាហេតុនាំអោយមានការយកចិត្តទុកដាក់លើគម្រោងសេវាសង្គមតិចតួច។
- ការចូលរួមរបស់ប្រជាពលរដ្ឋនៅមានកម្រិត ការសិក្សាខ្លះថាមកពីសង្កាត់និមួយៗអាចអនុវត្តគម្រោងតែមួយ ឬពីរក្នុងមួយឆ្នាំ។
- ឃុំ សង្កាត់កាន់តែមានការងារ និងតួនាទីកាន់តែច្រើនឡើង។ ក្រៅពីការកសាង និងអនុវត្តផែនការអភិវឌ្ឍន៍ ៥ឆ្នាំ និងផែនការវិនិយោគ ៣ឆ្នាំរំកិល និងការផ្តល់សេវាមូលដ្ឋាន ឃុំសង្កាត់ត្រូវចូលរួមអនុវត្តគោលនយោបាយ ភូមិ ឃុំមានសុវត្ថិភាព ចូលរួមក្នុការចុះឈ្មោះបោះឆ្នោត។

## ៣. គោលនយោបាយភូមិ ឃុំមានសុវត្ថិភាព

របាយការណ៍របស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទីមួយ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ បានលើកឡើងថា គ្រឿងញៀនបានបង្កបញ្ហាជាច្រើនដល់សង្គមដូចជា ចោរកម្ម ប្លន់ អំពើហឹង្សាផ្សេងៗ ។ល។[5] ផ្នែកនេះពិនិត្យមើលស្ថានភាពនៃការប្រើប្រាស់ គ្រឿងញៀនខុសច្បាប់នៅភ្នំពេញ និងបញ្ហាផ្សេងៗទៀតពាកព័ន្ធនឹងគ្រឿងញៀន។

<u>ស្ថានភាពនៃការប្រើប្រាស់គ្រឿងញៀនខុសច្បាប់នៅភ្នំពេញ (ឆ្នាំ២០១៣ ដល់ ២០១៥)</u>




*ប្រភព៖ ឯកសារព័ត៌មានស្ថានភាពស្ដីពី សេដ្ឋកិច្ច សង្គមកិច្ចឆ្នាំ ២០១៦ រាជធានីភ្នំពេញ និងប្រព័ន្ធទិន្នន័យឃុំ សង្កាត់ របស់ គ.ជ.អ.ប*

តួលេខខាងលើបានបង្ហាញថា លើកលែងតែខណ្ឌចំការមនចេញដែលមានអត្រាការប្រើប្រាស់គ្រឿងញៀនមានកម្រិតទាប ខណ្ឌផ្សេងៗទៀតមានអត្រាកើនឡើងជាលំដាប់ ហើយខណ្ឌជ្រោយចង្វាមានអត្រាកើនឡើងខ្ពស់ជាងគេ។ របាយការណ៍ប្រចាំខែរបស់នគរបាលរាជធានីភ្នំពេញបានបង្ហាញថា បទល្មើសគ្រឿងញៀនចំនួន ៤៦៣ករណី ត្រូវបានបង្ក្រាប ដែលកើនឡើងចំនួន ២៥៥ករណីពីឆ្នាំ ២០១៤។[6] នេះបង្ហាញថានគរបាលបានបង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការងារប្រយុទ្ធប្រឆាំងនឹងបញ្ហាគ្រឿងញៀន។




*ប្រភព៖ ឯកសារព័ត៌មានស្ថានភាពស្ដីពី សេដ្ឋកិច្ច សង្គមកិច្ចឆ្នាំ ២០១៦ រាជធានីភ្នំពេញ និងប្រព័ន្ធទិន្នន័យ ឃុំ សង្កាត់ របស់ គ.ជ.អ.ប*

## ការអប់រំ ការទប់ស្កាត់ និងការស្តានិតិសម្បទា

ខណៈដែលមានមានការរំពឹងទុកខ្ពស់ដែលថាសង្កាត់ចូលរួមការអនុវត្តន៍គោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព សង្កាត់មានសមត្ថភាពនៅមានកម្រិត និងមានតួនាទីបំពេញបន្ថែមដល់នគរបាល ដែលជាតួអង្គសំខាន់ក្នុការអនុវត្តន៍គោលនយោបាយនេះ។[7] តួនាទីសង្កាត់រួមមាន ចូលរួមរៀបចំវេទិកា ដើម្បីលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព និងការទប់ស្កាត់បទល្មើស រៀបចំបណ្តាញប្រជាការពារដែលជាអ្នកស្ម័គ្រចិត្ត ធ្វើការអប់រំប្រជាពលរដ្ឋ និងធ្វើការជាមួយនគរបាលសង្កាត់ពាក់ព័ន្ធនឹងការអបរំ និងការទប់ស្កាត់បទល្មើស។

បើយោងតាមរបាយការណ៍របស់ក្រុមសមាជិកព្រឹទ្ធសភា ប្រចាំភូមិភាគទីមួយ អាជ្ញាធរមូលដ្ឋាន ព្យាយាមដោះស្រាយបញ្ហាគ្រឿងញាន តាមរយៈ ការអនុវត្តន៍ច្បាប់ ការអប់រំ និងសេវាកម្មព្យាបាល និងស្តានិតិសម្បទានៅតាមសហគមន៍។[8] បន្ថែមលើសពីនេះទៀត របាយការណ៍របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបង្ហាញថានៅភ្នំពេញ កម្មវិធីផ្សព្វផ្សាយអំពីសារាំង និងម្សុលចាក់ថ្នាំត្រូវបានអនុវត្ត បដាអប់រំអំពីគ្រឿងញៀនត្រូវបានដំឡើងនៅតាមមណ្ឌលសុខភាព និងកម្មវិធីអប់រំនៅតាមសាលារៀន តាមវិទ្យុ ទូរទស្សន៍ និងការប្រគុំតន្ត្រី ត្រូវបានអនុវត្ត។[9] ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រឿងញៀន កម្លាំងបួនប្រភេទត្រូវបានប្រើប្រាស់៖ (១) កម្លាំងចំហរ (២) កម្លាំងល្បាត (៣) កម្លាំងអន្តរាគមន៍ និង (៤) កម្លាំងពួនស្ទាក់ ទាំងពេលថ្ងៃ និងពេលយប់។[10]

*បញ្ហាប្រឈម*

- ដូចដែលបានគត់សម្គាល់ខាងលើ សង្កាត់ត្រូវឆ្លើយតបនឹងការរំពឹងទុកខ្ពស់របស់ប្រជាពលរដ្ឋ ខណៈដែលពួកគេមានតួនាទីជាអ្នកជំនួយពាក់ព័ន្ធនឹងគោលនយោបាយភូមិឃុំមានសុវត្ថិភាព។ ការអនុវត្តន៍គោលនយោបាយភូមិឃុំមានសុវត្ថិភាពដោយជោគជ័យ ពឹងផ្អែកទៅលើគុណភាពនៃការអនុវត្តន៍ការងាររបស់នគរបាលសង្កាត់ និងការសហការគ្នារវាងរដ្ឋបាល និងនគរបាលសង្កាត់។
- លើសពីនេះទៀត ការពិនិត្យមើលផែនការរបស់សង្កាត់ បានបង្ហាញថាពុំមានថវិកាត្រូវបានវិភាជសម្រាប់ការអនុវត្តសកម្មភាពគោលនយោបាយភូមិ ឃុំមាន សុវត្ថិភាពទេ។
- មានសេវាកម្មព្យាបាល និងស្តានិតិសម្បទា សម្រាប់ការព្យាបាល និងស្តានិតិសម្បទាប្រហែល ៣% នៃអ្នកប្រើប្រាស់គ្រឿងញៀន អាស្រ័យហេតុនេះមានសេចក្តីត្រូវការសេវាបន្ថែមទៀត និងការសហការល្អរវាងអជ្ញាធរមូលដ្ឋាន និងអ្នកផ្តល់សេវាកម្មនេះ។[11]

- ពុំមានប៉ុស្តិ៍នគរបាល និងមន្ត្រីនគរបាលគ្រប់គ្រាន់ កងសន្តិសុខខណ្ឌ និងបណ្តាញការពារប្រជាការពារ[12] ហើយជាពិសេសខ្វះខាតការលើកទឹកចិត្ត សម្ភារៈសម្រាប់ការប្រតិបត្តិការរបស់ពួកគេ។[13]
- យន្តការដើម្បីតាមដានការប្រើប្រាស់គ្រឿងញៀន និងការអនុវត្តច្បាប់នៅថ្នាក់មូលដ្ឋានពុំមានលក្ខណៈរឹងមាំនៅឡើយ។
- ការបណ្តុះបណ្តាលមន្ត្រីថ្នាក់មូលដ្ឋាន និងមន្ត្រីអនុវត្តច្បាប់នៅមានកម្រិត។[14]

## ៤. ការចូលរួមរបស់សង្កាត់ក្នុងការងារចុះឈ្មោះបោះឆ្នោត

ក្រុមប្រឹក្សាឃុំ សង្កាត់បានធ្វើការសហការជាមួយក្រុមចុះឈ្មោះបោះឆ្នោត ដែលជាផ្នែកមួយនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ តួនាទីសំខាន់របស់ឃុំ សង្កាត់ រួមមានដូចជា ការកំណត់ចំនួននៃការិយាល័យចុះឈ្មោះបោះឆ្នោត ចំនួនអ្នកដែលទទួលបានសិទ្ធិបោះឆ្នោត ធ្វើការសង្កេតទៅលើដំណើរចុះឈ្មោះ ធានាអោយបានថាមានអ្នកសង្កេតការណ៍មកពីគ្រប់គណបក្សនយោបាយ ធ្វើការចេញឯកសារបញ្ជាក់អត្តសញ្ញាណ និងទទួលពាក្យបណ្តឹងជាដើម។[15]

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានធ្វើការប៉ាន់ស្មានថាចំនួនអ្នកដែលទទួលបានសិទ្ធិបោះឆ្នោតមានប្រមាណ ៩,៦៦៤,២១៦នាក់។[16] ការចុះឈ្មោះបោះឆ្នោតសម្រាប់ការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០១៧ បានចាប់ផ្តើមចាប់តាំងពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦។ នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ចំនួនប្រជាពលរដ្ឋដែលបានចុះឈ្មោះមានចំនួន ៧,៨៣២,៧២១នាក់ (ដែលស្មើនឹង ៨១.០៤% នៃចំនួនអ្នកដែលទទួលបានសិទ្ធិបោះឆ្នោតសរុប) ហើយ ៥៣.៥៤% គឺជាស្ត្រី។[17]

បញ្ហាប្រឈមមួយចំនួនត្រូវបានកំណត់ឡើង ពាក់ព័ន្ធទៅនឹងការចុះឈ្មោះបោះឆ្នោត រួមមានដូចជា៖

- ក្រសួងមហាផ្ទៃគ្រោងនឹងចេញ ១០,៩លាន អត្តសញ្ញាណប័ណ្ណអោយបានមុនការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០១៧។[18] មកដល់ពេលនេះអត្តសញ្ញាណប័ណ្ណ ៦.៤លាន ត្រូវបានចែកចាយ ដែលមានន័យថា អត្តសញ្ញាណប័ណ្ណ៤លាន ទៀតនឹងត្រូវចេញឲ្យបាន មុនការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០១៧។[19] បន្ថែមពីនេះទៅទៀត អត្តសញ្ញាណប័ណ្ណមួយចំនួនដែលបានចេញនៅក្នុងឆ្នាំ២០១២ ត្រូវបានរបក និងទាមទារអោយមានការប្តូរថ្មីឲ្យបានមុនការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០១៧។[20]

- ប្រជាពលរដ្ឋដែលកាន់អត្តសញ្ញាណប័ណ្ណចាស់ និងអត្តសញ្ញាណប័ណ្ណថ្មីត្រូវបានអនុញ្ញាតអោយចុះឈ្មោះ ដែលបណ្តាលអោយមានការព្រួយការបារម្ភថានឹងមានការចុះឈ្មោះស្ទួន ដោយហេតុថាអត្តសញ្ញាណប័ណ្ណចាស់មិនមានបន្ទះឈីប (Biometric Chip) ដែលផ្ទុកនូវទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកកាន់។[21]
- យោងទៅតាមអ្នកនាំពាក្យរបស់ គ.ជ.ប ដំណើរការនៃការចុះឈ្មោះបោះឆ្នោតបានជួបប្រទះនឹងបញ្ហាតិចតួចដូចជា៖ (១) កង្វះអគ្គីសនីនៅក្នុងឃុំមួយចំនួននៅតាមជនបទដែលតម្រូវឲ្យទិញម៉ាស៊ីនភ្លើងចំនួន ៨០គ្រឿង[22] (២) កង្វះបទពិសោធន៍នៃប្រតិបត្តករកុំព្យូទ័រ (Computer Operator) នៅតាមឃុំមួយចំនួន និងទី (៣) ការតភ្ជាប់ប្រព័ន្ធអ៊ីនធឺណែតមានសភាពយឺតយ៉ាវនៅតាមឃុំមួយចំនួន ដែលធ្វើអោយមានការលំបាកក្នុងការបញ្ជូនទិន្នន័យតាមរយៈប្រព័ន្ធអ៊ីនធឺណែត។[23] ទោះជាយ៉ាងណាបញ្ហាតូចតាចទាំងនេះត្រូវបានដោះស្រាយ។

# ៥. សេចក្តីសន្និដ្ឋាន

វិមជ្ឈការ និងវិសហមជ្ឈការកំណែទម្រង់នៅកម្ពុជាទើបតែចាប់ផ្តើមថ្មីៗនេះ។ ប៉ុន្តែអាជ្ញាធរមូលដ្ឋានដូចជា ឃុំ សង្កាត់ បានដំណើការពេញលេញ ហើយបាននិងកំពុងទទួលតួនាទី និងការទទួលខុសត្រូវនិងថវិការកាន់តែច្រើនឡើងៗ។ ក្រៅពីការកសាង និងអនុវត្តផែនការអភិវឌ្ឍន៍ ៥ឆ្នាំ និងកម្មវិធីវិនិយោគ ៣ ឆ្នាំរំកិល និងការផ្តល់សេវាមូលដ្ឋាន ឃុំ សង្កាត់ត្រូវចូលរួមអនុវត្តគោលនយោបាយ ភូមិ ឃុំមានសុវត្ថិភាព ចូលរួមក្នុការចុះឈ្មោះបោះឆ្នោត។ ដើម្បីដោះស្រាយបញ្ហាប្រឈមរបស់សង្កាត់ ពួកគេត្រូវការការគាំទ្រច្រើន ទាងខាង ថវិកា ការកសាងសមត្ថភាព និង ការសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលមូលដ្ឋានផ្សេងទៀត។

# ឯកសារយោង

---

[1] Trimester Report on the implementation of the 1st 3-year implementation plan (2011-2013) is the report on the implementation of activities of the Capital of Phnom Penh.
[2] NCDD 2015b. Project Implementation Database. Phnom Penh.
[3] NCDD 2015a. Commune/Sangkat Contract Implementation Detail. *In:* NCDD (ed.). Phnom Penh.
[4] PIC 2016a. CCWC's Roles, Responsibilities and Procedures for Budget Requests and Budget Expenditure. Parliamentary Institute of Cambodia.
[5] PISITPITO, K. 2016. Report on the implementation of governmental policy on three topics: serving public service, village-sangkat safety and local development in Phnom Penh. Phnom Penh: Senate.
[6] TITTHARA, M. 2016. *Drug Arrests Up in Capital: Report* [Online]. Phnom Penh: Khmer Times Available: http://www.khmertimeskh.com/news/23414/drug-arrests-up-in-capital--report/ [Accessed September 23, 2016.
[7] PIC 2016b. Enhancing Local Development of Sangkat in Phnom Penh. Parliamentary Institute of Cambodia
[8] PISITPITO, K. 2016. Report on the implementation of governmental policy on three topics: serving public service, village-sangkat safety and local development in Phnom Penh. Phnom Penh: Senate.
[9] NACD 2015. The result of monitoring drug. Phnom Penh.
[10] SOKUNTHEARY, S. 2015. Report on discussion between Senate Members of Region 1 and local level of 12 Khan in Phnom Penh from 05 March to 25 June, 2015 Phnom Penh: Senate.
[11] PISITPITO, K. 2016. Report on the implementation of governmental policy on three topics: serving public service, village-sangkat safety and local development in Phnom Penh. Phnom Penh: Senate.
[12] Ibid.
[13] SOKUNTHEARY, S. 2015. Report on discussion between Senate Members of Region 1 and local level of 12 Khan in Phnom Penh from 05 March to 25 June, 2015 Phnom Penh: Senate.
[14] NACD 2015. The result of monitoring drug. Phnom Penh.
[15] NEC 2016a. Directive and Procedure for Voter Registration to Develop Voter Lists 2016. *In:* COMMITTEE, N. E. (ed.), ibid.
[16] NEC, T. 2016b. Press Release: Provisional results of the registered voters in order to prepare voter list 2016. 17 October 2016 ed. Phnom Penh.
[17] Ibid.
[18] SHAUN, T. & VIDA, T. 2015. ID cards coming unglued. *The Phnom Penh Post*, 24 November 2015.
[19] VIDA, T. Ibid.Million more new ID cards required. 19 November 2015.
[20] SHAUN, T. & VIDA, T. Ibid.ID cards coming unglued. 24 November 2015.
[21] SOKCHEA, M. & SHAUN, T. Ibid.NEC Concerned over new IDs. 5 June 2015.
[22] NAREN, K. 2015. Pilot for New Voter Registration System Identifies Key Problems. *The Cambodia Daily*, November 10 2015.
[23] SOKHA, T., SENGKONG, B. & TURTON, S. 2016. 'Smooth' day for NEC as opening of voter registration sees just minor issues. *The Phnom Penh Post*, 02 September 2016.